# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ 258 ប្រក.កសក

## ប្រកាស

ស្តីពី

ការធ្វើនេសាទក្តាម និង ក្រែងឈាម នៅក្នុងដែននេសាទសមុទ្រ

នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ប្រកាសលេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និង សមុទ្រ
- បានឃើញ ប្រកាសលេខ ០០០២ ប្រក.កសក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៨៩ ស្តីពីអង្គការមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទ វារីវប្បកម្ម កែច្នៃជលផល និងការអនុញ្ញាតពិសេស
- តាមសំណើរបស់ នាយកដ្ឋានជលផល

## សម្រេច

**ប្រការ១** : ការធ្វើនេសាទក្តាម និង ក្រែងឈាម នៅក្នុងដែននេសាទសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារ ។

**ប្រការ២** : ត្រូវហាមឃាត់ :

១. ការធ្វើនេសាទក្តាម ដោយប្រើប្រាស់ឧបករណ៍ទាំងឡាយណាធ្វើពីសាច់អួន ឬ សាច់មង ដែលមានក្រឡាតូចជាង ៦ស.ម ។

២. ការធ្វើនេសាទក្រែងឈាម ដោយប្រើប្រាស់ឧបករណ៍ទាំងឡាយណាធ្វើពីសាច់អួន ឬ សាច់មង ដែលមានក្រឡាតូចជាង ២ស.ម ។

៣ ការធ្វើអាជីវកម្មនេសាទ ការទិញ ការលក់ សន្និធិ ឬ ការដឹកជញ្ជូន :

ក- ក្តាមថ្ម ដែលមានប្រវែងស្នូក ខ្លីជាង ៨ ស.ម ឬ ច្រើនជាង ១០ក្បាលក្នុង១ គីឡូក្រាម ។

ខ- ក្តាមសេះ និង ក្តាមខ្លា ដែលមានប្រវែងស្នូក ខ្លីជាង ៩ស.ម ឬ ច្រើនជាង ២០ក្បាលក្នុង១ គីឡូក្រាម ។

គ- ក្រែងឈាម ដែលមានប្រវែងខ្លីជាង ២ ស.ម ឬច្រើនជាង៣០០គ្រាប់ក្នុង ១គីឡូក្រាម ។

**ប្រការ៣** : ជនណាដែលបានប្រព្រឹត្តល្មើសនឹងប្រការ១ ឬ/និង ប្រការ២ នៃប្រកាសនេះ ត្រូវផ្តន្ទាទោសតាមមាត្រា៣៨ មាត្រា៣៩ ឬ មាត្រា៤០ នៃក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ។

**ប្រការ៤** : ជនណាឆ្លៀតយកឥទ្ធិពល និង អំណាចនៅក្នុងមុខងាររបស់ខ្លួន ដើម្បីប្រព្រឹត្តបទល្មើស ឬ ឃុបឃិត បិទបាំង ការពារអំពើល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦** : អគ្គនាយក នៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋាន កិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការ អន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង និងប្រធានការិយាល័យជលផលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សាលាខេត្ត ក្រុង ពាក់ពន្ធ័
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ